ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៨ លេខ ០៩

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាព ការងារ

ECOSOCC

គសវ



Work Activities

ប្រចាំខែកញ្ញា ឆ្នាំ២០១៥



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិច | ១ |
| ២- | កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ | ៣ |
| ៣- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំខែសីហា ឆ្នាំ២០១៥ | ៥ |
| ៤- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១៣ |

## សេចក្តីព្រាងអនុក្រឹត្យស្តីពី

# ការគ្រប់គ្រងបរិក្ខារអគ្គិសនី និងអេឡិចត្រូនិច

សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិចត្រូវបានដាក់ឆ្លងកិច្ចប្រជុំជំនាញបច្ចេកទេសចំនួន ០៤លើក ដឹកនាំដោយឯកឧត្តម **ឆយ អួន** សមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **សុភ ផេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់។ បន្ទាប់ពីបានបញ្ចប់កិច្ចប្រជុំជំនាញបច្ចេកទេស សេចក្តីព្រាងនេះត្រូវបានដាក់ឆ្លងកិច្ចប្រជុំអន្តរក្រសួង និងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ មុននឹងដាក់ឆ្លងសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។

សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិច ត្រូវបានរៀបចំដោយក្រសួងបរិស្ថាន ដែលមានគោលបំណងគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិចប្រកបដោយសុវត្ថិភាពបរិស្ថាន និងមានគោលដៅគ្រប់គ្រងឲ្យមានប្រសិទ្ធភាពនូវសំណល់អគ្គិសនីនិងអេឡិចត្រូនិចចាប់ពីចំណុចបង្កើតរហូតដល់ការបោះចោលចុងក្រោយ ទប់ស្កាត់ការនាំចូលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិចដើម្បីបោះចោល កាត់បន្ថយការនាំចូលសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិចដែលប្រើប្រាស់រួច ដែលនៅមានគុណភាពប្រើប្រាស់បាន និងទប់ស្កាត់ការសាយភាយសារធាតុគ្រោះថ្នាក់ពីសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិចចូលក្នុងបរិស្ថានទឹក ដី និងខ្យល់។



ក្នុងកំឡុងពីរទសវត្សចុងក្រោយនេះ ការអភិវឌ្ឍប្រទេសជាតិបានឈានទៅមុខជាលំដាប់លើគ្រប់វិស័យពិសេសវិស័យសេដ្ឋកិច្ច អភិវឌ្ឍន៍ទីក្រុង ឧស្សាហកម្ម និងទេសចរណ៍។ ការរីកចម្រើននេះគឺជាការឆ្លុះបញ្ចាំងអំពីការដឹកនាំដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ជាប្រមុខ។ ទន្ទឹមនឹងការយកចិត្តទុកដាក់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ រាជរដ្ឋាភិបាលក៏បានចាត់ទុកការទប់ស្កាត់ការបំពុលបរិស្ថានដែលកើតចេញពីដំណើរការអភិវឌ្ឍទាំងនោះ ដោយបានកំណត់ក្នុងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល អំពីការធានាបាននូវ

ប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានទឹកគ្មានការបំពុល និងនៅក្នុងគោលដៅនៃផែនទីបង្ហាញផ្លូវសម្រាប់ការអភិវឌ្ឍន៍បៃតងជាតិ ដែលបានកំណត់នៅក្នុងចំណុចទី២ អំពីការទទួលបានសន្តិសុខស្បៀងនិងផលិតផលគ្មានជាតិគីមី។

ដោយសារកំណើនវិស័យសេដ្ឋកិច្ច អភិវឌ្ឍន៍ទីក្រុង ឧស្សាហកម្ម និងការកើនឡើងនៃចំនួនប្រជាជនដ៏ឆាប់រហ័សនៅក្នុងពិភពលោក ដែលជាកត្តាធ្វើឲ្យមានតម្រូវការប្រើប្រាស់នូវឧបករណ៍ និងសម្ភារៈប្រចាំថ្ងៃកាន់តែសំបូរបែប និងកើនឡើងជាលំដាប់។ ទន្ទឹមនោះ ការអភិវឌ្ឍខាងវិស័យបច្ចេកវិទ្យាបរិក្ខារអគ្គិសនី និងអេឡិចត្រូនិចក៏បាននឹងកំពុងវិវត្តន៍កាន់តែទំនើប ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការប្រើប្រាស់។ ជាការពិតណាស់បច្ចេកវិទ្យាបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិច គឺជាផ្នែកមួយរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងជួយបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាងដល់ការរស់នៅប្រចាំថ្ងៃរបស់ប្រជាជន។ ទន្ទឹមនោះ វាក៏ជាក្ដីកង្វល់សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ក្នុងការធានាឲ្យមានប្រសិទ្ធភាព និងនិរន្តរភាពដល់ការគ្រប់គ្រងសំណល់ប្រភេទនេះនៅពេលដែលវាអស់មានតម្លៃប្រើប្រាស់បន្តទៀត។ នាប៉ុន្មានឆ្នាំចុងក្រោយនេះ ប្រភេទបរិក្ខារអគ្គិសនី និងអេឡិចត្រូនិចចាស់ៗ ដែលប្រើរួច ឬ សំណល់នៅតាមបណ្ដាប្រទេសជឿនលឿនភាគច្រើន ត្រូវបាននឹងកំពុងដឹកជញ្ជូនឆ្លងដែនមកលក់នៅទីផ្សារក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍តាមរូបភាពផ្សេងៗក្នុងសកម្មភាពស្របច្បាប់ផងនិងខុសច្បាប់ផង ដើម្បីស្វែងរកទីតាំងបោះបង់ចោល។

សម្រាប់ព្រះរាជាណាចក្រកម្ពុជាយើង ការហូលចូលនូវបរិក្ខារអគ្គិសនី និងអេឡិត្រូនិចទាំងនោះ ក៏កំពុងមានការកើនឡើងយ៉ាងខ្លាំងពីមួយឆ្នាំទៅមួយឆ្នាំ ជាពិសេសបរិក្ខារអគ្គិសនី និងអេឡិត្រូនិចដែលប្រើប្រាស់រួចហើយ(ជជុះ)។ កំណើននៃការប្រើប្រាស់នេះ បានផ្ដល់ក្ដីបារម្ភចំពោះការគ្រប់គ្រងសំណល់ បន្ទាប់ពីប្រើប្រាស់រួច ឬបំណែកសេសសល់ពីការជួសជុល ពីព្រោះសំណល់ទាំងនោះ ត្រូវបានចាត់ទុកជាប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ ដោយមានផ្ទុកនូវសារធាតុបំពុលបរិស្ថានមួយចំនួនដូចជា ពពួកលោហៈធ្ងន់ និងពពួកសារធាតុបំពុលសរីធាតុបំពុលសរីរាង្គមិនងាយបំបែកធាតុជាដើម ប្រសិនបើការគ្រប់គ្រងពុំបានអនុវត្តតាមគោលការណ៍ណែនាំបច្ចេកទេសត្រឹមត្រូវ។

អង្គប្រជុំជាបន្តបន្ទាប់បានពិនិត្យពិភាក្សាលើសេចក្ដីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្ដីព្រាងនេះកាន់តែល្អ។

(១) អត្ថបទនេះដកស្រង់ពីសេចក្ដីព្រាងសេចក្ដីថ្លែងហេតុរបស់សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រងបរិក្ខារអគ្គិសនីនិងអេឡិចត្រូនិច។

# កិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ

កាលពីថ្ងៃពុធ ទី២៣ ខែកញ្ញា ឆ្នាំ២០១៥ នៅវេលាម៉ោង ១៧:០០នាទី នៅទីស្ដីការគណៈរដ្ឋមន្ត្រី បានបើកអង្គប្រជុំត្រួតពិនិត្យចុងក្រោយ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្ដមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដោយមានការអញ្ជើញចូលរួមពី ឯកឧត្ដម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងសមាជិក ECOSOCC ឯកឧត្ដម **សយ សុខា** អគ្គលេខាធិការរាជរដ្ឋាភិបាល ក្រុមប្រឹក្សាអ្នកច្បាប់ អគ្គលេខាធិការរាជរដ្ឋាភិបាល ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** សាមីក្រសួង និងតំណាងក្រសួងពាក់ពន្ធ័ ដើម្បីពិនិត្យពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

១- សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រងសំណល់បរិក្ខាអគ្គិសនីនិងអេឡិចត្រូនិច។

២- សេចក្ដីព្រាងគោលនយោបាយជាតិ ស្ដីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា។

៣- បញ្ហាផ្សេងៗ




ក្រោយពីបានពិនិត្យពិភាក្សាផ្លាស់ប្ដូរយោបល់គ្នា អង្គប្រជុំបានសម្រេចដូចខាងក្រោម៖

**១- សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិច៖**



មាត្រា៥ កថាខណ្ឌទី៤ បន្ថែមពាក្យ **"ធ្វើប្រព្រឹត្តកម្ម"** បន្ទាប់ពីពាក្យផលិតកម្មនៃការ និង បន្ថែមឃ្លា **"បន្ទាប់ពីមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមហើយ"** បន្ទាប់ពីពាក្យអគ្គិសនី និងអេឡិចត្រូនិច។

២- សេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា៖

ក្រោយពីបានពិនិត្យ និងពិភាក្សាយ៉ាងល្អិតល្អន់រួចមក អង្គប្រជុំបានសម្រេចកែពាក្យ **"អត្តពលិក"** ទៅជាពាក្យ **"កីឡាករ កីឡាការិនី"** នៅគ្រប់ចំណុចទាំងអស់ដែលប្រើពាក្យនេះ។ ក្រៅពីកែសម្រួលនេះ អង្គប្រជុំបានឯកភាពតាមសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡា ដែលក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំស្នើឡើងមកនេះ។

អង្គប្រជុំត្រួតពិនិត្យចុងក្រោយបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងទាំងពីរនេះ នៅវេលាម៉ោង ១៨:៣០នាទី ក្រោមបរិយាកាសរីករាយនិងស្និទ្ធស្នាលបំផុត។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែសីហា ឆ្នាំ២០១៥*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌កម្ពុជា **ប្រចាំខែសីហា ឆ្នាំ២០១៥**នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៥ ដឹកនាំដោយ ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីអនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែសីហាឆ្នាំ២០១៥ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង ០,៣% ធៀបនឹងខែមុន និងកើនឡើង ០,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| ក្រុមទំនិញ: | | មុខទំនិញ: | |
|---|---|---|---|
| ភោជនីយដ្ឋាន: | +៤,២% | ត្រីស្រស់: | +៨,៦% |
| សំលៀកបំពាក់ និងស្បែកជើង: | +៤,២% | បន្លែ: | +៣,៤% |
| ការកម្សាន្ត និងវប្បធម៌: | +៣,៥% | អង្ករ: | +២,០% |
| ម្ហូបអាហារ: | +៣,១% | សាច់មាន់: | +១,៩% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +២,៧% | ផ្លែឈើ: | +១,១% |
| គ្រឿងសង្ហារឹម និងសម្ភារៈប្រើប្រាស់ | +២,០% | សាច់ជ្រូក: | +១,០% |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៣–២០១៥

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា[P] | តុលា[P] | វិច្ឆិកា[P] | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៥ | ដូចគ្នាឆ្នាំមុន | 0,៤% | ១,៦% | ១,១% | ១,៣% | ១,0% | 0,៧% | 0,៨% | 0,៨% | 0,៨% | 0,៩% | 0,៩% | | |
| | មុន | -0,៤% | ១,២% | 0,១% | 0,៧% | 0,១% | 0,២% | 0,៦% | 0,៣% | 0,២% | -0,៣% | -0,៨% | | |
| ២០១៤ | ដូចគ្នាឆ្នាំមុន | ៤,៥% | ៤,៣% | ៥,0% | ៤,៩% | ៤,៦% | ៤,៩% | ៤,២% | ៤,១% | ៣,៦% | ២,៩% | ២,៤% | ២,៥% | ៤,0% |
| | មុន | 0,២% | 0 | 0,៥% | 0,៥% | 0,៣% | 0,៥% | 0,៤% | 0,៣% | 0,២% | -0,៤% | -0,៨% | 0,៧% | |
| ២០១៣ | ដូចគ្នាឆ្នាំមុន | ១,៨% | ១,៧% | ១,0% | ១,0% | ២,៨% | ២,៩% | ៤,0% | ៣,៣% | ៣,៩% | ៤,២% | ៤,១% | ៤,៧% | ៣,0% |
| | មុន | 0,៣% | 0,២% | -0,១% | 0,៦% | 0,៧% | 0,២% | ១% | 0,៤% | 0,៧% | 0,២% | -0,៣% | 0,៥% | |

**P:** តួលេខខែ កញ្ញា តុលា និងវិច្ឆិកា ឆ្នាំ២០១៥ ជាតួលេខព្យាករ (តាមវិធីសាស្ត្រ **DECOMPOSITION)**

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់







តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | សីហា២០១៥ | កក្កដា២០១៥ | សីហា២០១៤ | *ប្រភេទ* | សីហា២០១៥ | កក្កដា២០១៥ | សីហា២០១៤ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤0៨១៛/$ | ៤១១៣៛/$ | ៤0៦៥៛/$ | **បាត/ដុល្លារ** | ៣៥,៨១បាត/$ | ៣៥,0៨បាត/$ | ៣១,៩៣បាត/$ |
| **៛/បាត** | ១១៤៛/បាត | ១១៧៛/បាត | ១២៧៛/បាត | **ដុង/ដុល្លារ** | ២២៤៦0ដុង/$ | ២១៨១១ដុង/$ | ២១១៧0ដុង/$ |
| **៛/ដុង** | 0,១៨៩៛/ដុង | 0,១៨៩៛/ដុង | 0,១៩២៛/ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិអគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារ ក្នុងខែសីហាឆ្នាំ ២០១៥ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម៖

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន៩៨២,៦ពាន់លានរៀល (*មធ្យមប្រចាំខែ ១០៥% នៃផែនការ*) ក្នុងនោះចំណូលចរន្ត ៩២៣,៣ពាន់លានរៀល(*មធ្យមប្រចាំខែ ១០១% នៃផែនការ*) និងចំណូលមូលធន៥៩,៣ពាន់លានរៀល(តួលេខរតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៣-២០១៥ (ពាន់លានរៀល)




➢បើធៀបនឹងខែមុនចំណូលថវិកាជាតិថយចុះ៩,៤%ប៉ុន្តែកើនឡើង២១,២% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន៧៩០,៧ ពាន់លានរៀល ថយចុះ១១,៥% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៩,៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ រតនាគារជាតិ)។

✓ចំណូលមិនមែនសារពើពន្ធមានចំនួន ១៣២,៦ពាន់លានរៀល កើនឡើង១១% ធៀបនឹងខែមុននិងកើនឡើង៦២,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ រតនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ**(តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: -២,៥% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+១៤,១%) | ➢ កាស៊ីណូ : -៣៩% | (+១២%) |
| | | ➢ អាជ្ញាបណ្ណក្នុងស្រុក : -៧៣,៥% | (+៧១៥,១%) |
| ➢ ចំណូលពន្ធដារ: -៣,១% (អគ្គនាយកដ្ឋានពន្ធដារ) | (-១,១៧%) | ➢កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ :+៨,៥% | (+២៧,៣% |
| | | ➢ នេសាទ:-៧,៤% | (១៦៦%) |
| | | ➢វុក្ខាប្រមាញ់: -៧២,២% | (+៦០,៤%) |
| | | ➢សម្បទានរ៉ែ: -២៨,៥% | (+៧%) |
| | | ➢ អាកាសចរណ៍ស៊ីវិល:+៨៧៦% | (+១៨%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: -៩៤,៤% | (-៩៣,៤%) |
| | | ➢ប្រៃសណីយ៍ និងទូរគមនាគមន៍: | |
| | | ➢អាករស្ពានទូក(លិខិតឆ្លងដែននិងទិដ្ឋាការ):-១៣,១% | (+៤២%) |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ១០៥៧,១ពាន់លានរៀល(*មធ្យមប្រចាំខែ ៥៤% នៃផែនការ*) ក្នុងនោះ ចំណាយចរន្ត ចំនួន ៨៨៧,៨ពាន់លានរៀល (*មធ្យមប្រចាំខែ ៧៣% នៃផែនការ*) និងចំណាយមូលធន ១៦៩,៤ ពាន់លានរៀល(តួលេខរតនាគារជាតិ)។

➢ចំណាយថវិកាជាតិកើនឡើង២,៨% ធៀបនឹងខែមុននិងកើនឡើង៤៦,៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង០,៩% ធៀបនឹងខែមុន និងកើនឡើង៥៥,៥%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានឱនភាពចំនួន **៧៤,៦**ពាន់លានរៀល (តួលេខរតនាគារជាតិ)។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៣–២០១៥




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែសីហាឆ្នាំ២០១៥មានលក្ខណៈដូចខាងក្រោម៖

➢រូបិយវត្ថុM₂ មានចំនួន៤៦៧០១ពាន់លានរៀលកើនឡើង១,៥% ធៀបនឹងខែមុន និងកើនឡើង១៦,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើងនៃ$M_2$** ក្នុងខែនេះ ជារួម បណ្តាលមកពីការកើនឡើងនៃប្រាក់បញ្ញើមានកាលកំណត់និងសន្សំ១៩,៨% និងប្រាក់បញ្ញើជារូបិយបណ្ណ១,៣%។

➢នាខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៦,៨% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន៨៣,២%នៃរូបិយវត្ថុ$M_2$។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែសីហាឆ្នាំ២០១៥




*តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ ឆ្នាំ២០១៥*

| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | ១៧,៩% | ១៨% | ១៧,៦% | ១៧,១% | ១៦,៥% | ១៦,១% | ១៦,៦% | ១៦,៨% | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១៣,៦% | ១៣,៧% | ១៣,៥% | ១៣,៣% | ១២,៦% | ១២,២% | ១២,៤% | ១២,២% | | | | |

➢**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**មានចំនួន ៤៦១៦លានដុល្លារ ថយចុះ០,១% ធៀបនឹងខែមុន និងកើនឡើង១៣,៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ១៤១៨១ ពាន់លានរៀលកើនឡើង២% ធៀបនឹងខែមុន និងកើនឡើង៦,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| ផ្តល់ដោយ | សីហា២០១៥ | កក្កដា២០១៥ | សីហា២០១៤ |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ពាន់លានរៀល) ក្នុងនោះ ជារៀល | ៤៤៧៧១ | ៤៥១៩៤ | ៣៣០៦២<br>៤៣៤ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ពាន់លានរៀល) | — | ១០៤៥៩ | ៧០៧៤ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៦៥% | ៦,៧៧% | ៥,៩៣% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៦,២០% | ១៦,២៣% | ១៦,១៤% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,៤០% | ៤,៣៨% | ៤,២៣% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៥៩% | ១១,៥៤% | ១១,៥១% |

## ៤) ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➡ក្នុងខែសីហាឆ្នាំ២០១៥ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម៖

➢**កសិកម្ម**:

✓នេសាទសម្រេចបាន៥៦ពាន់តោន កើនឡើង៨%ធៀបនឹងខែមុន និងកើនឡើង៣៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓ អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន៥១៤,២GWHមានការកើនឡើង២%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង២៦%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គសនីមានចំនួន៣៧៤,១GWH មានការកើនឡើង៩%ធៀបនឹងខែមុន និងកើនឡើង១៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន៦៣៩,៦លានដុល្លារមានការថយចុះ៣%ធៀបនឹងខែមុន និង កើនឡើង៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន –សីហា២០១៥ | ចំនួន–កក្កដា២០១៥ | ចំនួន–សីហា២០១៤ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ១៨ | ៩ | ១២ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៤០០ | ១៣៨៣ | ១២២៨ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | | | ១៧ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | | | |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ១០៩១,៥ពាន់ម$^{២}$ កើនឡើង៣១៣%ធៀបនឹងខែមុននិងកើនឡើង ១២៣% ធៀបនឹងខែដូចគ្នាឆ្នាំមុន។បើគិតជាសាច់ប្រាក់ស្មើនឹង៥៣១,៤លានដុល្លារកើនឡើង៤៨២% ធៀបនឹងខែមុននិងកើនឡើង២៤៧%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ក្នុងនោះប្រភេទសំណង់ចម្បងៗមាន៖

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម² —សីហា២០១៥ | ពាន់ម² —កក្កដា២០១៥ | ពាន់ម² —សីហា២០១៤ |
|---|---|---|---|
| ▪ លំនៅឋាន | ៨៦២,៩ | ៩២,១ | ២៤៨,៥ |
| ▪ ឧស្សាហកម្ម | ៥៣,១ | ៨៦,៦ | ១៩៤,៨ |
| ▪ទេសចរណ៍ | ១៩,៩ | ៦៩ | ១៨,៤ |
| ▪ពាណិជ្ជកម្ម | ១១៣,៤ | ១២,៣ | ១០,៩ |
| ▪ផ្សេងៗ | ២,៤ | ០,០ | ១៦,៩ |
| អនុញ្ញាតសរុប | ១០៩១,៥ | ២៦៤,៥ | ៤៩០,១ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺលំនៅដ្ឋាន៧៩% និងពាណិជ្ជកម្ម ១០,៤%នៃផ្ទៃក្រឡាសរុប។

### ➢ការងារ

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់—សីហា២០១៥ | នាក់—កក្កដា២០១៥ | នាក់—សីហា២០១៤ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបបនិងការងារ ) | ៧០៧ | ៦០៤ | ១៨៨៨ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៨៩៦១ | ១១៦៨១ | ៩៦០៩ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៧៨៨៩ | ៩៤៥៧ | ៧៦០៨ |
| អ្នកទទួលបានការងារក្រៅប្រទេស | ១០៧២ | ២២២៤ | ១៩៩៨ |

### ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | សីហា២០១៥ | កក្កដា២០១៥ | សីហា២០១៤ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៥១,៥ | ២៣៦,២ | ១៦៣,៣ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ២៦ | ៧៦,៨ | ៣១,៥ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខ | ២៥,៥ | ៨៩,៧ | ៨៧,៨ |
| នៃតំបន់សេដ្ឋកិច្ចពិសេស) | ៣,១ | ១ | ៨,៩ |
| វិស័យទេសចរណ៍ | ០ | ០ | ០ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ៦៩,៧ | ៤៣,៩ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ៨ | ២៣ | ២៤ |
| បង្កើតការងារ (ពាន់នាក់) | ៥,៦ | ៣០,៦ | ២៥,១ |

### ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន—សីហា២០១៥ | ចំនួន—កក្កដា២០១៥ | ចំនួន—សីហា២០១៤ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៤៩២ | ៤០៥ | ៣៣២ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ៤ | ១១ | ៣ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | | ១២៦ | ៤២១ |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៥៩២,៥ពាន់តោនថយចុះ៩% ធៀបនឹងខែមុននិងថយចុះ១៣% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះ៖

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចក: បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញ:+១៥% | (+៨១%) | ▪ កំពង់ផែស្រែអំបិល និងកោះកុង:-៣២% | (-៧៤%) |
| ▪ កំពង់ផែកំពង់សោម:-១៩% | (-១៣%) | ▪ កំពង់ផែឧកញ៉ាម៉ុង: +១៣% | (-៥៦%) |

➢**ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍**

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| *ប្រភេទ* | *ចំនួន(ពាន់នាក់)* | *%Δ ធៀបនឹងខែមុន* | *%Δធៀបនឹងខែដូចគ្នាឆ្នាំមុន* |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១៥,៣ | +៧០% | +៤១% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៣៦,៤ | +៩% | +៧២% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៤៦៨,៥ | +៩% | +១០% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១០៨,៣ | +១២% | +៣៣% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៣៦៦,១ | +០% | +៥% |
| ✓ តាមផ្លូវអាកាស | ២០៤,៣ | +៥% | +១៤% |
| ✓ តាមផ្លូវគោក និងទឹក | ១៦១,៨ | -៥% | -៣% |

## ៥) ស្ថានភាពជញ្ជីងពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែសីហាមានចំនួន ៤៤៣៤,៦ពាន់លានរៀល (ស្មើនឹង ១១០៨,៦លានដុល្លារ ស.រ.អា.)ថយចុះ៣,៧% ធៀបនឹងខែមុនប៉ុន្តែកើនឡើង២២,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ៖

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹង ខែមុន | %Δធៀបនឹងខែ ដូចគ្នាឆ្នាំមុន | ទំនិញ | %Δ□ធៀបនឹង ខែមុន | %Δធៀបនឹងខែ ដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | ០% | +១៤,២% | រថយន្តសរុប (ព.ល.រ) | -៤% | +៣,៧% |
| ប្រេងម៉ាស៊ូត | +២,៥% | -០,៥% | រថយន្តសរុប (គ្រឿង) | +៤,៨% | +១៦,៨% |
| ឧស្ម័ន | -២៥,៧% | +០,៣% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -២៦,៣% | -៥៣,៩% |
| អគ្គិសនីនាំចូល | -៤,៨% | +៥,៥% | ម៉ូតូ (គ្រឿង) | | |
| ដែកសំណង់ | +៤៦,៧% | +១០៨% | អង្ករ | -៩,៤% | +៣៤៣,៩% |
| ស៊ីម៉ង់ត៍ | -២៩,៧% | -២៨% | ផ្លែឈើនិងបន្លែ | -១៨,២% | -៣២% |
| គ្រឿងអេឡិចត្រូនិក | | | ជីនិងថ្នាំកសិកម្ម | +៣៤,៦% | -១៧% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | +៨,៥% | +៤២,៩% |

➡ **ការនាំចេញ** ខែសីហាឆ្នាំ២០១៥ មានចំនួន**៣៥១៥,១**ពាន់លានរៀល ស្មើនឹង**៨៧៨,៨**លានដុល្លារ ស.រ.អា. (**៧៩,៣**% នៃការនាំចូល)ថយចុះ១៤,៣% ធៀបនឹងខែមុនប៉ុន្តែកើនឡើង៥,៨%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %ធៀបនឹងខែមុន | %ធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | -៩០% | -៩០,៦% | ផលិតផលនេសាទ | -២៨,៣% | -៦៥,៩% |
| វាយនភណ្ឌនិងស្បែកជើង | -៩,៧% | +៦,៨% | កៅស៊ូ | +១% | +៣៤,៩% |
| អង្ករ | -៦,៨% | -១៦,៥% | | | |

➡ក្នុងខែសីហានេះជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន ៩១៩,៥៣ពាន់លានរៀលស្មើនឹង២២៩,៨លានដុល្លារ ស.រ.អ.។

## ៦) ការប្រែប្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែសីហាឆ្នាំ២០១៥នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ទុនវិនិយោគអនុញ្ញាតដោយក.អ.ក. | -៧៨% | -៦៨% | — |
| ២ | ទំនិញដឹកជញ្ជូនតាមផែ | -៩% | -១៣% | — |

## ៧) សេចក្តីសន្និដ្ឋាន

១) **ស្ថានភាពថ្លៃ**: ជារួម មកដល់ខែសីហាឆ្នាំ២០១៥នេះ អត្រាកំណើនសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់មានកម្រិតទាប ០,៨% ធៀបនឹងខែសីហាឆ្នាំ២០១៤ និងអតិផរណា ១% ប៉ុណ្ណោះ បើប្រៀបធៀប៨ខែដូចគ្នា ឆ្នាំ២០១៥ និង ២០១៤។ យ៉ាងណាមិញ នៅមានមុខទំនិញដែលមានការឡើងថ្លៃខ្ពស់ គួរឲ្យកត់សម្គាល់ ដូចជាត្រីស្រស់ និងបន្លែ។ អត្រាអតិផរណាទាបនេះ មានការរួមចំណែកនៃថ្លៃប្រេងឥន្ធនៈក្នុងទីផ្សារសកលលោក ប៉ុន្តែមានការកត់សម្គាល់ថា ការចុះថ្លៃនៃប្រេងឥន្ធនៈនៅកម្ពុជានៅមិនទាន់សមស្របទៅនឹងការចុះថ្លៃប្រេងឆៅនៅទីផ្សារសកលលោកនៅឡើយទេ។

២) **វារីវប្បកម្មត្រី**: មានការឯកភាពថា ត្រូវបង្កើនវារីវប្បកម្មត្រីឲ្យបានទូលំទូលាយ និងធ្វើពិពិធកម្មប្រភេទត្រីចិញ្ចឹមព្រមទាំងគួរពិនិត្យឡើងវិញនូវបទប្បញ្ញត្តិអំពីលទ្ធភាពចិញ្ចឹមត្រីឆ្តោរ និងត្រីរស់។

៣) **ការងារ**: អង្គប្រជុំកត់សំគាល់ថា បច្ចុប្បន្នពលករជាតិមួយចំនួនធំ បានធ្វើចំណាកស្រុកស្វែងរកកម្រៃពលកម្មនៅក្រៅប្រទេស ដែលជាហេតុធ្វើឲ្យអោយផលិតកម្មក្នុងស្រុកខ្លះមានការខ្វះខាតកម្លាំងពលកម្ម។ ទន្ទឹមនឹងនេះ ក៏មានការហូរចូលនៃពលកម្មបរទេសក្នុងវិស័យមួយចំនួនទៅវិញ។ និន្នាការនេះ បើគ្មានវិធានការទប់ស្កាត់ត្រឹមត្រូវ អាចនឹងប៉ះពាល់ដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥។

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១៥

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០១/០៩/១៥<br>ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង និងក្រុមការងារបច្ចេកទេសដោះស្រាយបញ្ហាសំណង់អនាធិបតេយ្យនៅជាប់របងជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដើម្បីស្តាប់របាយការណ៍បូកសរុបចុងក្រោយរបស់ក្រុមហ៊ុន Green Goal នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២ | ០២/០៩/១៥<br>ម៉ោង០៧:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងមហាសន្និបាតតំណាងសមាគមអតីតយុទ្ធជនកម្ពុជាទូទាំងប្រទេសលើកទី២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានសមាគមអតីតយុទ្ធជនកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅវិទ្យាស្ថានជាតិអប់រំ។ |
| ៣ | ០២/០៩/១៥<br>ម៉ោង១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ២០១៥-២០២៥។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | ០៣/០៩/១៥<br>ម៉ោង០៩:៣០នាទី | ទទួលជួបប្រជុំពិភាក្សាការងារជាមួយសមាជិកថ្មី ឯកឧត្តម **យស់ ស៊ីម៉ារ៉ាត** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៥ | ០៤/០៩/១៥<br>ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងអនុក្រឹត្យ ស្តីពីវិធានការសុខាភិបាលដើម្បីទប់ស្កាត់ និងឆ្លើយតបការឆ្លងរាលដាលជាអន្តរជាតិនៃជំងឺនៅតាមច្រកចេញចូល។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ២០១៥-២០២៥។<br>៣-បញ្ហាផ្សេងៗ ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៦ | ០៩/០៩/១៥<br>ម៉ោង០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់សញ្ញាបត្របណ្ឌិតកិត្តិយស " **ភាពជាអ្នកដឹកនាំឆ្នើម** " ពីសាកលវិទ្យាល័យ លីម កុកវីង នៃប្រទេសម៉ាឡេស៊ី ជូនសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៧ | ១០/០៩/១៥<br>ម៉ោង០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីប្រគល់ប្រាក់រង្វាន់លើកទឹកចិត្តរបស់រាជរដ្ឋាភិបាលជូនដល់ជ័យលាភីការប្រកួតកីឡាស៊ីហ្គេមលើកទី២៨ និងការប្រកួតកីឡាអន្តរជាតិនានា ក្រោមអធិបតីភាព ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិទ្យាស្ថានជាតិអប់រំ។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១៥ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៨ | ១១/០៩/១៥<br>ម៉ោង០៩:៣០នាទី | ទទួលជួបប្រជុំពិភាក្សាការងារជាមួយសមាជិកថ្មី ឯកឧត្តម **ម៉ិន ណារិទ្ធ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ១៤/០៩/១៥<br>ម៉ោង០៩:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់បរិក្ខាអគ្គិសនីនិងអេឡិចត្រូនិក។<br>២-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ១៤/០៩/១៥<br>ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតក្រុមវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | ១៥/០៩/១៥<br>ម៉ោង០៩:១៥នាទី | បន្តដឹកនាំកិច្ចប្រជុំ ដើម្បីពិនិត្យលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតក្រុមវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១២ | ១៥/០៩/១៥<br>ម៉ោង១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ឌិន វីរៈ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៣ | ១៦/០៩/១៥<br>ម៉ោង១០:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ម៉ិច សុខា** ស្តីពីគម្រោងវិនិយោគការសាងសង់អគារសារមន្ទីរសព្វទស្សន៍អង្គរ នៅបន្ទប់ឯកឧត្តមប្រធាន(ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | ១៧/០៩/១៥<br>ម៉ោង០៩:៣០នាទី | បន្តជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ម៉ិច សុខា** ស្តីពីគម្រោងវិនិយោគការសាងសង់អគារសារមន្ទីរសព្វទស្សន៍អង្គរ នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ១៧/០៩/១៥<br>ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ប្រចាំខែសីហា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ២១/០៩/១៥<br>ម៉ោង០៨:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និបាតបូកសរុបការងារប្រឡងប្រណាំង "រមណីយដ្ឋានស្អាត សេវាល្អ ឆ្នាំ២០១៤" ក្រោមអធិបតីភាព ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ជាតំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ។ |
| ១៧ | ២១/០៩/១៥<br>ម៉ោង១៥:៣០នាទី | ជួបប្រជុំពិភាក្សាការងារអំពីការសាងសង់អគារសារមន្ទីរសព្វទស្សន៍ ជាមួយលោក Kim អ្នកគ្រប់គ្រងក្រុមហ៊ុន ម៉ាន់ស៊ូដេញតិច នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម **យឹម ណុលឡា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកញ្ញា ឆ្នាំ២០១៥ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៨ | **២២/០៩/១៥ ម៉ោង០៩:៣០នាទី** | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **យឹម ណុលសន** និងឯកឧត្តម **ម៉ិច សុខា** ស្តីពីគម្រោងវិនិយោគការសាងសង់អគារសារមន្ទីរសព្វទស្សន៍អង្គរ នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៩ | **២២/០៩/១៥ ម៉ោង១៤:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបការងារប្រឡងប្រណាំង "រមណីយដ្ឋានស្អាត សេវាល្អ ឆ្នាំ២០១៤" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ។ |
| ២០ | **២៣/០៩/១៥ ម៉ោង០៩:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់បរិក្ខាអគ្គិសនីនិងឡិចត្រូនិក។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយជាមួយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២១ | **២៣/០៩/១៥ ម៉ោង១៧:០០នាទី** | ចូលរួមជាសមាជិក ក្នុងកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ សម្រាប់ប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់បរិក្ខាអគ្គិសនីនិងអេឡិចត្រូនិក។<br>២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអភិវឌ្ឍវិស័យអប់រំកាយនិងកីឡា។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២២ | **២៨/០៩/១៥ ម៉ោង០៩:០០នាទី** | ដឹកនាំកិច្ចប្រជុំការងារផ្ទៃក្នុងរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឆ្នាំ២០១៥ នៅទីស្តីការ គណៈរដ្ឋមន្ត្រី។ |
| ២៣ | **២៩/០៩/១៥ ម៉ោង០៨:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រចាំខែសីហា ឆ្នាំ២០១៥ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៤ | **៣០/០៩/១៥ ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងាររៀបចំបញ្ញត្តិ ស្តីពីការអនុវត្តការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ដើម្បីពិនិត្យចុងក្រោយលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៥ | **៣០/០៩/១៥ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in